ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៨ សរ

## សារាចរ
## ស្តីពី
## ការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

យោងព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី អនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន អនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន និងផ្អែកលើស្នូលនៃ"**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១**" ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលផ្តោតលើអភិបាលកិច្ចនិងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ព្រមទាំងដើម្បីជានាឱ្យបាននូវការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នមានប្រសិទ្ធភាពខ្ពស់ឈរលើ**អភិក្រមពង្រឹងនិងការរៀបចំផ្ទះរបស់ខ្លួនឱ្យរៀបរយ** រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការពាក់ព័ន្ធនឹងការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

### ១. គោលការណ៍នៃការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធ

- ការពង្រឹងនិងការរៀបចំឱ្យបានរៀបរយនូវរចនាសម្ព័ន្ធដែលមានស្រាប់៖ ក្រសួង ស្ថាប័នត្រូវពិនិត្យនិងរៀបចំរចនាសម្ព័ន្ធដែលមានស្រាប់ឱ្យបានរៀបរយ ដោយប្រើប្រាស់ឱ្យអស់នូវលទ្ធភាពនិងសក្តានុពលក្នុងការកែលម្អការអនុវត្តមុខងារដែលជាសមត្ថកិច្ចរបស់ខ្លួន ការរៀបចំរចនាសម្ព័ន្ធឱ្យបានសមស្របក្នុងការគាំទ្រការអនុវត្តមុខងារ និងការរៀបចំលំហូរការងារក្នុងក្រសួង ស្ថាប័ន ព្រមទាំងការកំណត់គណនេយ្យភាពនិងការទទួលខុសត្រូវច្បាស់លាស់ក្នុងការបំពេញការងារ
- **ការរក្សាចំនួនអង្គភាព៖** ការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន មិនត្រូវនាំឱ្យមានការបង្កើនចំនួនអង្គភាពទោះក្នុងកម្រិតណាមួយក៏ដោយ ឬបន្ថែមទម្ងន់បែបបទនិងនីតិវិធីដែលមានស្រាប់នៅតាមអង្គភាពរបស់ក្រសួង ស្ថាប័នឡើយ។ ក្រសួង ស្ថាប័ន ត្រូវពិនិត្យឡើងវិញរចនាសម្ព័ន្ធមានស្រាប់ដែលមិនឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ននិងក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦នៃរដ្ឋសភា ដើម្បីធ្វើការកែសម្រួលឬច្របាច់បញ្ចូលគ្នាឬលុបចោល។ ដោយឡែក

ការបង្កើតអង្គភាពថ្មី ត្រូវផ្អែកលើហេតុផលច្បាស់លាស់ ដើម្បីប្រសិទ្ធភាពការងារនិងឆ្លើយតបនឹងការតម្រូវដែលមានក្នុងក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧នៃរដ្ឋសភា

- ការរក្សានូវកម្រិតឬឋានៈអង្គភាព៖ ការរៀបចំនិងកែសម្រួលរចនាសម្ព័ន្ធដែលមានស្រាប់របស់ក្រសួង ស្ថាប័ន មិនត្រូវធ្វើការដំឡើងកម្រិតឬឋានៈអង្គភាព ដែលជាហេតុនាំឱ្យមានការកើនរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នឡើយ
- ការធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ធនធានមនុស្សនិងថវិកា៖ ការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ត្រូវអនុវត្តដើម្បីធានាឱ្យបាននូវការគ្រប់គ្រងនិងប្រើប្រាស់ធនធានមនុស្សនិងថវិកាប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ២. ការរៀបចំ ការបង្កើត និងការកែសម្រួលរចនាសម្ព័ន្ធ

- ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន រួមទាំងការបង្កើតនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ត្រូវអនុវត្តដោយផ្អែកលើលក្ខខណ្ឌនៃការពិនិត្យឡើងវិញជារួមនូវមុខងារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងរចនាសម្ព័ន្ធដែលមានស្រាប់ រួមទាំងរចនាសម្ព័ន្ធចំណុះក្រសួង រដ្ឋលេខាធិការដ្ឋាន និងរចនាសម្ព័ន្ធរបស់ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងយន្តការនានា ដែលក្រសួងនិងរដ្ឋលេខាធិការដ្ឋានត្រូវទទួលបន្ទុក
- ការបង្កើតនិងការកែសម្រួលក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ ឬអង្គភាពថ្មី ដើម្បីបំពេញបេសកកម្មនិងមុខងារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ក្រសួង ស្ថាប័ននោះត្រូវប្រើប្រាស់រចនាសម្ព័ន្ធគ្រប់គ្រងដែលមានស្រាប់របស់ក្រសួង ស្ថាប័ន ធ្វើជាលេខាធិការដ្ឋាន ដោយមិនត្រូវបង្កើតឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងអចិន្ត្រៃយ៍ថ្មីឡើយ លើកលែងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលត្រូវបង្កើតអនុលោមបទប្បញ្ញត្តិដែលមានកំណត់ក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័នត្រូវធ្វើការពិនិត្យឡើងវិញនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីធានាឱ្យការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មានដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់ ឆ្លើយតបនឹងខ្លឹមសារនៃសារាចរនេះ។

## ៣. បែបបទនិងនីតិវិធីនៃការពិគ្រោះយោបល់

- ក្រសួង ស្ថាប័នត្រូវលើកសំណើនៃការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនមកក្រសួងមុខងារសាធារណៈដើម្បីពិគ្រោះយោបល់អនុលោមបទប្បញ្ញត្តិដែលមានកំណត់ក្នុងអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- បន្ទាប់ពីបានឆ្លងការពិគ្រោះយោបល់ខាងលើរួច សំណើរបស់ក្រសួង ស្ថាប័នត្រូវដាក់ឆ្លងកិច្ចប្រជុំនានា ដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទទួលបានការពិនិត្យនិងផ្តល់យោបល់ពីគ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ អនុលោមតាមបែបបទនិងនីតិវិធីជាធរមាន
- ទីស្តីការគណៈរដ្ឋមន្ត្រី លើកសំណើដែលបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់រួចរាល់ ជូននាយករដ្ឋមន្ត្រី ពិនិត្យនិងសម្រេច។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៥ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ